[09]

# Good Luck and Fate

**Q.** ***What did the Buddha teach about magic and fortune telling?***

**A.** The Buddha considered such practices as fortune telling, wearing magic charms for protection, finding lucky sites for buildings, prophesising and fixing lucky days to be useless superstitions and he expressly forbade his disciples to practise such things. He called all these things 'low arts'. "*Whereas some religious men, while living off food provided by the faithful make their living by such low arts, such wrong means of livelihood as palmistry, divining by signs, interpreting dreams, bringing about good or bad luck, picking the lucky site for a building, the monk Gotama refrains from such low arts, such wrong means of livelihood*".

**Q.** ***Then why do people sometimes practise such things and believe in them?***

**A.** Because of greed, fear and ignorance. As soon as people understand the Buddha's teachings, they realise that a pure heart can protect them much better than bits of paper, bits of metal and a few chanted words and they no longer rely on such things. In the teachings of the Buddha, it is honesty, kindness, understanding, patience, forgiveness, generosity,

ភាគ ៩

# សំណាងល្អ និង សំណាងអាក្រក់

**ប្ញ.** *តើព្រះពុទ្ធជាម្ចាស់បង្រៀនអ្វីខ្លះ អំពីមហិទ្ធិឫទ្ធិនិងការទោះទាយ?*

**ទិ.** ព្រះពុទ្ធបរមគ្រូពិចារណាការបដិបត្តិដូច្នោះថាជាការទោះទាយ ពាក់គាថាការពារ ទាយប្លង់ដី មើលហោរាសាស្ត្រនិងកាត់គ្រោះហ៍ គឺជាជំនឿអរូបីយ៍ឥតប្រយោជន៍ ហើយព្រះអង្គហាមប្រាមសាវ័កទាំងឡាយរបស់ព្រះអង្គមិនឱ្យបដិបត្តិវត្ថុដូចនេះ។ ព្រះពុទ្ធអង្គហៅវិជ្ជាទាំងអស់នេះថា " ជាវិទ្យាសិល្បះថ្នាក់ទាប" ។ " មានអ្នកសាសនាខ្លះ ក្នុងខណៈដែលមានជីវិតរស់នៅដោយអាស្រ័យបាយទឹកនំចំណីរបស់អ្នកម្ចាស់ទាន ដែលបានមកពីការប្រើវិទ្យាសិល្បះថ្នាក់ទាបដូចនេះ មុខរបរដែលខុសដូចនោះមានដូចជាទាយបាតដៃ ស័កចារ ទាយសុបិន្តនិមិត្ត ស្រោចទឹកកាត់គ្រោះហ៍ ទាយប្លង់ដី សមណគោត្តមវៀរចាកពីការប្រើវិទ្យាសិល្បះថ្នាក់ទាបយ៉ាងនេះ វៀរចាកពីការចិញ្ចឹមជីវិតដោយវិធីខុសយ៉ាងនេះ" ។

**ប្ញ.** *បើដូច្នោះ ហេតុអ្វីពេលខ្លះមនុស្សបដិបត្តិដូចនោះ ហើយជឿនូវវិជ្ជាសិល្បះទាំងនោះ?*

**ទិ.** ពីព្រោះតែសេចក្តីលោភលន់ សេចក្តីភ័យខ្លាចនិងអវិជ្ជា។ ពេលមនុស្សយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គកាន់តែរហ័ស ពួកគេនឹងភ្ញាក់ខ្លួនថាបេះដូងពិតប្រាកដអាចការពារពួកគេបានច្រើនជាងផែនក្រដាស ផែនមេដែក និងពាក្យសូត្រអាគមន៍គាថាមួយម៉ាត់ពីរម៉ាត់ ហើយពួកគេនឹងមិនពឹងពាក់ទៅលើវត្ថុទាំងនោះបន្តទៀតឡើយ ។ នៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ វាគឺសេចក្តីស្មោះត្រង់ សន្តានចិត្តល្អ ការយល់ដឹង អត់ធន់ អភ័យទោស ចិត្តសប្បុរសធម៌

loyalty and other good qualities that truly protect you and give you true prosperity.

**Q.** ***But some lucky charms do work, don't they?***

**A.** I know a person who makes a living selling lucky charms. He claims that his charms can give good luck, prosperity and he guarantees that you will be able to pick three numbers. But if what he says is true then why isn't he himself a multi-millionaire? If his lucky charms really work, then why doesn't he win the lottery week after week? The only luck he has is that there are people silly enough to buy his magic charms.

**Q.** ***Then is there such a thing as luck?***

**A.** The dictionary defines luck as 'believing that whatever happens, either good or bad, to a person in the course of events is due to chance, fate or fortune'. The Buddha denied this belief completely. Everything that happens has a specific cause or causes and there must be some relationships between the cause and the effect. Becoming sick, for example, has specific causes. One must come into contact with germs and one's body must be weak enough for the germs to establish themselves. There is a definite relationship between the cause (germs and a weakened body) and the effect (sickness) because we know that germs attack the organisms and give rise to sickness. But no relationship can be found between wearing a piece of paper

ភក្តីភាព និងសភាពល្អៗផ្សេងទៀតដែលអាចការពារអ្នកបានពិតប្រាកដ និងផ្តល់ឱ្យអ្នកនូវភិយ្យោភាពយ៉ាងពិតប្រាកដ ។

**សុ.** ***តែវេទមន្តភ័ព្វសំណាងខ្លះជួយបានពិត មែនទេ?***

**ចិ.** ខ្ញុំស្គាល់មនុស្សម្នាក់ដែលចិញ្ចឹមជីវិតដោយការលក់វេទមន្តភ័ព្វសំណាង។ គាត់អះអាងថាវេទមន្តរបស់គាត់អាចធ្វើឱ្យសំណាងល្អ រីកចំរើន ហើយគាត់ធានាថាអ្នកនឹងអាចត្រូវឆ្នោតរង្វាន់លេខបី។ តែបើអ្វីដែលគាត់និយាយជារឿងពិត ចុះហេតុអ្វីបានជាខ្លួនគាត់ផ្ទាល់មិនក្លាយជាមហាសេដ្ឋីទៅ?។ បើវេទមន្តភ័ព្វសំណាងរបស់គាត់ពិតជាជួយពិតប្រាកដមែន ចុះហេតុអ្វីក៏គាត់មិនឈ្នះឆ្នោតរាល់សប្តាហ៍ទៅ?។ ភ័ព្វសំណាងតែម្យ៉ាងដែលគាត់មានគឺមានមនុស្សឆ្កួតសន្ធោសចំនួនគ្រប់គ្រាន់ល្មម បានទិញវេទមន្តសក្តិសិទ្ធិរបស់គាត់ ។

**សុ.** ***ដូច្នោះ តើមានវត្ថុដូចនេះអាចជាភព្វ័សំណាងទេ?***

**ចិ.** វចនានុក្រមអោយនិយមន័យពាក្យ ឡាក់ថា " ជំនឿដែលអ្វីក៏ដោយនឹងកើតឡើងទាំងល្អ និងអាក្រក់ ចំពោះមនុស្សដែលស្ថិតនៅក្នុងហេតុការណ៍ទាំងឡាយអាស្រ័យទៅលើកាលៈទេសៈជោគវាសនាឬភព្វ័សំណាង" ។ ព្រះពុទ្ធបរមគ្រូបដិសេធន៏ជំនឿបែបនេះទាំងស្រុង។ អ្វីគ្រប់យ៉ាងដែលកើតឡើង មានមូលហេតុឬមូលហេតុទាំងឡាយពិតប្រាកដ ហើយត្រូវតែមានការទំនាក់ទំនងខ្លះរវាងហេតុនិងផល។ សំរាប់ជាឧទាហរណ៏ ពេលយើងធ្លាក់ខ្លួនឈឺ មានមូលហេតុពិតប្រាកដរបស់វា។ មនុស្សដែលឈឺពិតជាបានឆ្លងមេរោគ ហើយរាងកាយអ្នកជំងឺពិតជាទន់ខ្សោយអាចធ្វើមេរោគកកំណើតខ្លួនវាបាន។មានទំនាក់ទំនងច្បាស់លាស់រវាងហេតុ (មេរោគ និងរាងកាយដែលទន់ខ្សោយ) និងផល (ការឈឺ) ពីព្រោះយើងដឹងថាមេរោគចូលទៅលុកលុយអវយវៈទាំងឡាយ ហើយធ្វើឱ្យធ្លាក់ខ្លួនឈឺ។ តែគ្មានទំនាក់ទំនងណាអាចត្រូវគេរកឃើញរវាង

with words written on it and being rich or passing examinations. Buddhism teaches that whatever happens does so because of a cause or causes and not due to luck, chance or fate. People who are interested in luck are always trying to get something, usually more money and wealth. The Buddha teaches us that it is far more important to develop our hearts and minds. He says:

Being deeply learned and skilled;
Being well-trained and
Using well-spoken words
This is the best good luck.
To support mother and father,
To cherish wife and child and
To have a simple livelihood
This is the best good luck.
Being generous, just,
Helping one's relatives and
Being blameless in one's actions
This is the best good luck.
To refrain from evil and from strong drink,
And to be always steadfast in virtue,
This is the best good luck.
Reverence, humanity, contentment,
Gratitude and hearing the good Dharma,
This is the best good luck.
Sn 261-265

ការពាក់ផែនក្រដាសជាមួយពាក្យដែលចារទុកលើនោះក្លាយជាអ្នកមានឬប្រឡងជាប់ឡើយ។ ព្រះពុទ្ធសាសនាបង្រៀនថាអ្វីក៏ដោយនឹងកើតឡើង កើតឡើងដូច្នេះពីព្រោះហេតុណាមួយឬហេតុទាំងឡាយ ហើយមិនអាស្រ័យទៅលើភព្វសំណាង កាលះទេសះឬជោគវាសនាឡើយ។ មនុស្សដែលចាប់អារម្មណ៍ទៅលើភព្វសំណាងជានិច្ចជាកាលគឺស្វះស្វែងរកវត្ថុមួយចំនួនដូចជា ជាធម្មតាត្រូវការលុយកាក់ឬក៏ទ្រព្យសម្បត្តិច្រើនថែមទៀត។ ព្រះពុទ្ធបរមគ្រូបង្រៀនយើងថាវាកាន់តែឆ្ងាយពីសារៈសំខាន់ក្នុងការអភិវឌ្ឍន៍បេះដូងនិងចិត្តគំនិតទាំងឡាយរបស់យើង ។ ព្រះអង្គត្រាស់ថា :

ជាអ្នកសិក្សារៀនសូត្រច្រើន និងមានឯកទេសជំនាញ, ជាអ្នកបានហ្វឹកហាត់លត់ដំល្អ
និយាយតែពាក្យដែលជាសុភាសិត, នេះគឺជាភព្វសំណាងល្អបំផុត ។
ចិញ្ចឹមបីបាច់មាតានិងបិតា, មើលថែទាំភរិយា និងបុត្រីបុត្រា និង
មានជីវិតរស់នៅយ៉ាងសាមញ្ញ, នេះគឺជាភព្វសំណាងល្អបំផុត ។
ជាអ្នកមានសន្ដានចិត្តល្អ មិនលំអៀង, ជួយឈឺឆ្អាលញាតិសន្ដានរបស់មិត្ត និង
ជាអ្នកមិនចេះស្ដីបន្ទោសជនដទៃ, នេះគឺជាភព្វសំណាងល្អបំផុត ។
វៀរចាកពីអំពើអាក្រក់និងផឹកទឹកស្រវឹង, និងជានិច្ចជាកាលតំកល់ខ្លួននៅក្នុងគុណធម៌
នេះគឺជាភព្វសំណាងល្អបំផុត ។
អោនលំទោន មានករុណាធម៌ សេចក្ដីរីករាយចិត្ត, ដឹងបុណ្យគុណនិងស្ដាប់ធម៌ជាប្រចាំ
នេះគឺជាភព្វសំណាងល្អបំផុត ។
សំយុត្តនិកាយ ២៦១-២៦៥